ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៦៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគ ប្តូរចំណាត់ថ្នាក់ ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- លិខិតលេខ ២២៦ សជណ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២០ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ ៧៩៩ សជណ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ ៤២ សជណ.សស ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ ៤៥២ សជណ.សស ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ ០៧៣ ស.អ.យ.ខ.រ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

-លិខិតលេខ ១៧០១ សជណ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី
-លិខិតលេខ ២៨០៧ សក.ហវ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២០ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន
-លិខិតលេខ ១០៦៩ សជណ.អស ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៩ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី
-លិខិតលេខ ២៨០៨ សក.ហវ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២០ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន
-លិខិតលេខ ៧៩៨ សជណ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២០ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី
-លិខិតលេខ ២៦៦៩ ដនស/រអប ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០ របស់ក្រសួងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-លិខិតលេខ ៤៦៦ សជណ.មយ ចុះថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២០ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី
-លិខិតលេខ ១៨០/២០ របក.ហក្រ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២០ របស់រដ្ឋបាលរាជធានីភ្នំពេញ
-លិខិតលេខ ១៤៨០ លស ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២០ របស់ក្រសួងមហាផ្ទៃ។

## សម្រេច

**មាត្រា ១.-**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ នូវទីតាំងដូចខាងក្រោម÷

-ទីតាំងមជ្ឈមណ្ឌលជាតិស្ដារលទ្ធភាពពលកម្មជនពិការគៀនឃ្លាំង របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានទំហំ ២១ ១៩៥ ម៉ែត្រក្រឡា ស្ថិតនៅភូមិគៀនឃ្លាំង សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ។

-ទីតាំងរោងចក្រផលិតឧបករណ៍សប្បនិម្មិត រណបភ្នំពេញ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា មានទំហំ ៤ ០២៧ ម៉ែត្រក្រឡា ស្ថិតនៅកែងផ្លូវបេតុង ក្នុងភូមិ៧ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ។

-ទីតាំងទីតាំងមណ្ឌលកុមារកំព្រា ខេត្តកែប របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានទំហំ ១៥ ៣៦២ ម៉ែត្រក្រឡា ស្ថិតនៅភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប។

-ទីតាំងបុរីកុមារ និងទីតាំងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តព្រះសីហនុ របស់ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា មានទំហំ ២២ ៤១៤ ម៉ែត្រក្រឡា ស្ថិតក្នុងភូមិ៣ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ហើយពន្ធ និងអាករផ្សេងៗពាក់ព័ន្ធនឹងការផ្ទេរកម្មសិទ្ធិកាន់កាប់ទីតាំងនេះ ជាបន្ទុករបស់រដ្ឋ។

-ទីតាំងមណ្ឌលកុមារកំព្រា ខេត្តព្រះសីហនុ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានទំហំ ១៤ ១៨៣ ម៉ែត្រក្រឡា ស្ថិតនៅភូមិ៤ សង្កាត់លេខ៤ ខណ្ឌមិត្តភាព ខេត្តព្រះសីហនុ។

-ទីតាំងដីអតីតកំពង់ចម្លងព្រែកតាមាក់ត្រើយខាងលិច របស់ក្រសួងសាធារណការនិងដឹកជញ្ជូន មាន ទំហំ ១៤ ៩៨៦ ម៉ែត្រក្រឡា ស្ថិតនៅភូមិកោះរកា ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្ដាល ។

-ទីតាំងដីអតីតកំពង់ចម្លងព្រែកតាមាក់ត្រើយខាងកើត របស់ក្រសួងសាធារណការ និងដឹកជញ្ជូន មាន ទំហំ ៧ ១១១,២៣ ម៉ែត្រក្រឡាស្ថិតក្នុងភូមិស្វាយអាត់លើ ឃុំព្រែកតាមាក់ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល។

-ទីតាំងចំនួន ២កន្លែង ស្មើ ៤ ឡូតិ៍ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងនោះ ទីតាំងទី១ មាន ៣ឡូតិ៍ ទំហំសរុប ២៤ ៨២៦ ម៉ែត្រក្រឡា ឡូតិ៍ទី១ ទំហំ ៦ ៦១១ ម៉ែត្រក្រឡា ឡូតិ៍ទី២ ទំហំ ៤៨៦ ម៉ែត្រក្រឡា និងឡូតិ៍ទី៣ ទំហំ ១៧ ៧២៩ ម៉ែត្រក្រឡា ស្ថិតនៅភូមិព្រែកតាគង់ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ និងទីតាំងទី២មាន ១ឡូតិ៍ ទំហំ ២៩ ២៧៨ ម៉ែត្រក្រឡា ស្ថិតនៅភូមិតំណាក់ធំ និងភូមិត្នោត សង្កាត់ស្ទឹងមានជ័យទី២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

-ទីតាំងភោជនីយដ្ឋានមេគង្គ និងស្ថានីយប្រេងឥន្ធនៈសូតីម៉ិចឫស្សីកែវ របស់ក្រសួងមហាផ្ទៃ មានដីទំហំ ៥ ៥៦៤,៤៨ ម៉ែត្រក្រឡា ស្ថិតនៅសង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

**មាត្រា២.-**

ការលុបទីតាំងដូចមានចែងក្នុងមាត្រា១ ចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រូវស្ថិតនៅក្រោមការចាត់ចែងតាមបែបបទ និងនីតិវិធីជាធរមាន ដោយក្រសួងមហាផ្ទៃ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**មាត្រា ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងរដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១៥ កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២ ខែ តុលា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៤
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ